**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២២៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់ និងកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ២១០ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើផលិតផលតេលសិលាមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេស លើមុខទំនិញមួយចំនួន

- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលអត្រាអាករពិសេស លើមុខទំនិញរថយន្តមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូក ១

## ការកំណត់ និងកែសម្រួលអត្រាពន្ធគយលើមុខទំនិញមួយចំនួន

**មាត្រា ១**.- កំណត់អត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- **0%** លើមុខទំនិញ **ឧបករណ៍តេស្តរហ័សមួយចំនួន និងថ្នាំងសូឡា** ចំនួន **០៣ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៣៨២២.១២.០០ ៣៨២២.១៩.០០ និង ៨៥៤១.៤៩.០០។

- **៧%** លើមុខទំនិញ **ឆ្នួនសុវត្ថិភាព ប្រដេះ កីប និងថ្នាំងអេក្រង់** ចំនួន **០៦ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៣៦០៣.១០.០០ ៣៦០៣.២០.០០ ៣៦០៣.៤០.០០ ៨៥២៤.៩១.០០ ៨៥២៤.៩២.០០ និង ៨៥២៤.៩៩.០០។

- **១៥%** លើមុខទំនិញ **គ្រឿងបន្លាស់ម៉ាស៊ីន អាគុយលីចូម និងជ្រូន** ចំនួន **១៤ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៤៧៩.៩០.៩០ ៨៥០៧.៦០.៩០ ៨៥២៩.៩០.៩៩ ៨៨០៦.១០.០០ ៨៨០៦.២១.០០ ៨៨០៦.២២.០០ ៨៨០៦.២៣.០០ ៨៨០៦.២៤.០០ ៨៨០៦.២៩.០០ ៨៨០៦.៩១.០០ ៨៨០៦.៩២.០០ ៨៨០៦.៩៣.០០ ៨៨០៦.៩៤.០០ និង ៨៨០៦.៩៩.០០។

- **៣៥%** លើមុខទំនិញ **អាហារកែច្នៃពីសាច់សត្វនានា** ចំនួន **០៤ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ១៦០១.០០.១០ ១៦០១.០០.៩០ ១៦០២.១០.១០ និង ១៦០២.១០.៩០។

**មាត្រា ២**.- ត្រូវបានកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- **ពី 0%** មក **៧%** លើមុខទំនិញ **ភាគបំណែកគ្រឿងអលង្ការកាឡៃ និងដែកសំប៉ែតមានភ្លី** ចំនួន **០២ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៧១១៧.១៩.៩០ និង ៧២០៨.៩០.១០។

- **ពី 0%** មក **១៥%** លើមុខទំនិញ **បារីអេឡិចត្រូនិច និងខ្សៀអេឡិចត្រូនិចប្រហាក់ប្រហែល** ចំនួន **០១ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៥៤៣.៤០.០០។

**មាត្រា ៣**.- ត្រូវបានកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- **ពី ១៥%** មក **0%** លើមុខទំនិញ **គ្រឿងបន្លាស់ម៉ាស៊ីន** ចំនួន **០២ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៤៣៤.៩០.០០ និង ៨៤៥៥.៩០.០០។

- **ពី ១៥%** មក **៧%** លើមុខទំនិញ **គ្រឿងបន្លាស់ម៉ាស៊ីន** ចំនួន **០៧ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៣៦០៣.៣០.០០ ៣៦០៣.៥០.០០ ៣៦០៣.៦០.០០ ៣៨១៦.០០.២០ ៨៤២២.៩០.១០ ៨៤២២.៩០.៩០ និង ៨៤២៤.៩០.១០។

- **ពី ៣៥% មក ៧% លើមុខទំនិញ ផ្ទាំងអេក្រង់ LCD ចំនួន ០១ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៥២៤.១១.០០។

## ជំពូក ២
## ការកំណត់ និងកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន

**មាត្រា ៤.-** ត្រូវបានកំណត់អត្រាអាករពិសេសលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- **0%** លើមុខទំនិញ **អេក្រង់របស់បរិក្ខារអេឡិចត្រូនិច** ចំនួន **០៣ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៥២៤.៩១.០០ ៨៥២៤.៩២.០០ និង ៨៥២៤.៩៩.០០។
- **១០%** លើមុខទំនិញ **គ្រឿងបន្លាស់វិទ្យុ និងទូរទស្សន៍** ចំនួន **០១ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៥២៩.៩០.៩៩។
- **៣០%** លើមុខទំនិញ **រថយន្តផ្សេងទៀត** ចំនួន **០២ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៧០៤.៤៣.៨៩ និង ៨៧០៤.៥២.៩៩។

**មាត្រា ៥.-** ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- **ពី ៥% មក 0%** លើមុខទំនិញ **ទោចក្រយានអគ្គិសនី** ចំនួន **០៣ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៧១១.៦០.១១ ៨៧១១.៦០.៩៤ និង ៨៧១១.៦០.៩៥។
- **ពី ១០% មក 0%** លើមុខទំនិញ **ឧបករណ៍សម្រាប់បំភ្លឺ ឬឱ្យសញ្ញា សម្រាប់ទោចក្រយាន និងកង់ប្រណាំង** ចំនួន **០៣ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៥១២.១០.០០ ៨៧១២.០០.១០ និង ៨៧១២.០០.៩០។
- **ពី ៤០% មក ២០%** លើមុខទំនិញ **យានកង់បីដឹកទំនិញ ប្រើសាំង ម៉ាស៊ូត ឬ Hybrid** ចំនួន **០៦ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៧០៤.២១.១៣ ៨៧០៤.២១.២៧ ៨៧០៤.៣១.១៣ ៨៧០៤.៣១.២៧ ៨៧០៤.៤១.២៧ និង ៨៧០៤.៥១.២៧។
- **ពី ៤០% មក ១០%** លើមុខទំនិញ **យានកង់បីដឹកទំនិញ និងរថយន្តដឹកទំនិញត្រូសារអគ្គិសនី** ចំនួន **០៤ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៧០៤.៦០.១១ ៨៧០៤.៦០.១២ ៨៧០៤.៦០.២១ និង ៨៧០៤.៦០.២២។
- **ពី ៥០% មក ២០%** លើមុខទំនិញ **យានកង់បីដឹកអ្នកដំណើរ** ចំនួន **០២ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៧០៣.៣១.៣១ និង ៨៧០៣.៣១.៩១។

**មាត្រា ៦.-** ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- **ពី 0% មក ២៥%** លើមុខទំនិញ **ផលិតផលបំភាយផ្សែងមានសារធាតុនីកូទីនសម្រាប់ហឺត ធុងហ្គាសរថយន្ត និងបារីអេឡិចត្រូនិច** ចំនួន **០៨ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ២៤០៤.១១.០០ ២៤០៤.១២.១០ ២៤០៤.១២.៩០ ២៤០៤.១៩.១០ ២៤០៤.១៩.២០ ៧៣១១.០០.២១ ៧៣១១.០០.២២ និង ៨៥៤៣.៤០.០០។

## ជំពូក ៣
## ការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញមួយចំនួន

**មាត្រា ៧.-** ត្រូវបានកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញនាំចេញមួយចំនួនដូចខាងក្រោម÷

- **ពី ១០%** មក **0%** លើមុខទំនិញ **ព្រុយត្រីឆ្លាមធ្វើរួច** ចំនួន **០១ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ជាធរមាន ក្នុងទីតាំងរងលេខ÷ ០៣០៥.៧១.១០។

## ជំពូក ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពី**ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២** តទៅ។

ថ្ងៃពុធ ១៣ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យ សម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា **៩**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ